# អង្គការអ្នកត្រួសត្រាយនៃកម្ពុជា

# របាយការណ៍បូកសរុប
# លទ្ធផលការងារប្រចាំឆ្នាំ២០២៣

<u>ប្រភពមូលនិធិ:</u>

WorldFish
eco soap bank
APDRA PISCICULTURE PAYSANNE
AFD
IRD Institut de Recherche pour le Développement FRANCE
cirad

## មាតិកា


១. អំពីអង្គការអ្នកត្រួសត្រាយនៃកម្ពុជា ....................................................................................3
២. ពត៌មានគម្រោង ....................................................................................7
២.១. ខេត្តសៀមរាប ....................................................................................7
២.២. ខេត្តកំពង់ធំ ....................................................................................7
៣. ពិពណ៌នាសង្ខេបពីការរីកចម្រើនរបស់គម្រោង ....................................................................................8
៤. របាយការណ៍ហិរញ្ញវត្ថុ ....................................................................................14
៥. បញ្ហាប្រឈម និង មេរៀនបទពិសោធន៍ ....................................................................................14
៥.១ បញ្ហាប្រឈម ....................................................................................14
៥.២ បទពិសោធន៍ ឬមេរៀនដែលរៀនសូត្រពីគម្រោង ....................................................................................15
៦. ផែនការទិសដៅការងារបន្ត ....................................................................................15
៧. ឧបសម្ព័ន្ធ៖ ....................................................................................1715-16

## ១. អំពីអង្គការអ្នកត្រួសត្រាយនៃកម្ពុជា

អង្គការអ្នកត្រួសត្រាយនៃកម្ពុជា (អ.ត.ក) ដែលមានឈ្មោះជាភាសាអង់គ្លេសគឺ Trailblazer Cambodia Organization (TCO) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មិនស្វែងរកប្រាក់ចំណេញ ដែលត្រូវបានបង្កើតឡើងដោយក្រុមអ្នកជំនាញខាងវិស័យកសិកម្ម និងអភិវឌ្ឍជនបទ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គម ដោយធ្វើការជាដៃគូរជាមួយ រាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។ អ.ត.ក បានចុះបញ្ជីទទួលស្គាល់នៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ តាមរយៈលិខិតទទួលស្គាល់លេខៈ ១០០២/សជណ និងបានធ្វើបច្ចុប្បន្នភាពឡើងវិញ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមានរយៈលិខិតទទួលស្គាល់លេខៈ១៥៦៧/ប្រក។ បច្ចុប្បន្ននេះ អ.ត.ក មានស្នាក់ការកណ្តាលនៅខេត្តសៀមរាប ហើយបាន និងកំពុងប្រតិបត្តិការនៅក្នុងទូទាំងខេត្តសៀមរាប និងមានការិយាល័យរងនៅក្នុងខេត្តកំពង់ធំ។

ជាមួយនឹងបទពិសោធន៍ យ៉ាងទូលំទូលាយជាងដប់ឆ្នាំ ក្នុងការអនុវត្តគម្រោងទាំងផ្នែកមនុស្សធម៌ និងការអភិវឌ្ឍន៍ អ.ត.ក បានទទួលជោគជ័យក្នុងការគ្រប់គ្រង និងអនុវត្តគម្រោងជាច្រើនទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ គម្រោងកែលម្អជីវភាពរស់នៅ និងសន្តិសុខស្បៀង គម្រោងពាក់ព័ន្ធនឹងអនាម័យ ទឹកស្អាត គម្រោងអប់រំជាដើម ដែលត្រូវបានគាំទ្រថវិកា និងជំនួយបច្ចេកទេសដោយម្ចាស់ជំនួយអន្តរជាតិ និងដៃគូមួយចំនួនរួមមាន USAID-WorldFish, UNDP, EU/IFAD ESB, AFD-APDRA, CIRAD, IRD, ADIC, EFF...។ល។

យើងមានផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំយ៉ាងជាក់លាក់ និងមានចក្ខុវិស័យយ៉ាងទូលំទូលាយដូចខាងក្រោម៖

- <u>**ចក្ខុវិស័យ**</u> ៖ "ចង់ឃើញគ្រួសារគោលដៅទាំងឡាយ រស់នៅប្រកបដោយភាពពេញបរិបូរណ៍"។
- <u>**បេសកកម្ម**</u> ៖ ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ក្នុងតំបន់គោលដៅ នៃប្រទេសកម្ពុជា និងចូលរួមកែលម្អគុណភាពជីវិតដល់គ្រួសារដែលរស់នៅទីនោះ។
- <u>**គោលដៅ**</u>

  អង្គការអ្នកត្រួសត្រាយនៃកម្ពុជា មានគោលដៅយុទ្ធសាស្ត្រសំខាន់ៗប្រាំគឺ៖
  - លើកកម្ពស់កម្រិតជីវភាព និងសុវត្ថិភាពស្បៀងដល់គ្រួសារគោលដៅ
  - បង្កើនការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព
  - លើកកំពស់សេវា និងមធ្យោបាយទឹកស្អាត និង អនាម័យ
  - បង្កើនការអប់រំនៅតំបន់គោលដៅ
  - កៀរគរធនធានដើម្បីនិរន្តភាពស្ថាប័ន ក្នុងការចូលរួមបំពេញនូវតំរូវការរបស់សហគមន៍
- <u>**គុណតម្លៃ**</u>
  - ការប្តេជ្ញាចិត្តខ្ពស់
  - ភាពស្មោះត្រង់

- ការទទួលខុសត្រូវ
- ការគោរព

- **<u>ក្រមសីលធម៌</u>**

បុគ្គលិកគ្រប់រូប គឺជាតំណាងនៃអង្គការអ្នកត្រួសត្រាយនៃកម្ពុជា ដូច្នេះរាល់ការសំដែងចេញនូវឥរិយាបថរបស់បុគ្គលិកម្នាក់ៗ ទាំងក្នុងអំឡុងពេលកំពុងបំពេញការងារ ក៏ដូចជាក្រៅម៉ោងបំពេញការងារ គួរមានការប្រុងប្រយ័ត្ន។ បុគ្គលិកទាំងអស់ត្រូវមានភាពសុច្ចរិតទៀងត្រង់ នៅក្នុងការបំពេញការងារ ការរស់នៅប្រចាំថ្ងៃរបស់ពួកគេរួមបញ្ចូលទាំង៖

- គោរពច្បាប់ជាតិជាធរមាន
- ប្រកាន់ខ្ជាប់នូវគុណតម្លៃទាំងបួនរបស់អង្គការអ្នកត្រួសត្រាយនៃកម្ពុជា
- ផ្តល់តម្លៃ ដល់បុគ្គលគ្រប់រូប ទាំងក្នុងអង្គការ និងខាងក្រៅ រួមទាំងកុមារផងដែរ
- សន្សំសំចៃ ថែរក្សាទ្រព្យសម្បត្តិរបស់អង្គការ
- មិនរើសអើង ប្រកាន់បក្សពួក
- មិនផ្សំគំនិតក្នុងការកេងបន្លំសាច់ប្រាក់ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ឬក្រុមខ្លួនឡើយ
- មិនប្រព្រឹត្ត ឬសហការប្រព្រឹត្តសកម្មភាពទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ការរស់នៅ និងការលូតលាស់របស់កុមារ។
- មិនប្រព្រឹត្តអាកប្បកិរិយាមិនសមរម្យ ដូចជាជក់បារី លេងល្បែងស៊ីសង សេពគ្រឿងស្រវឹង ឬគ្រឿងញៀន។
- ហាមដាច់ខាតការបង្ករឿងហេតុប្រទូស្តរាយ ឬញុះញង់បង្កឲ្យមានអំពើហឹង្សាដែលធ្វើឲ្យខូចសណ្តាប់ធ្នាប់ និងអន្តរាយដល់អង្គការ។
- មិនរំលោភបំពានផ្លូវកាយបុគ្គល ឧទាហរណ៍ បុគ្គលិកយកដៃទះគូចបុគ្គលិកម្នាក់ទៀត។
- មិនត្រូវធ្វើកាយវិការបង្ហាញពីការបៀតបៀនកេរ្តិ៍ខ្មាស់។
- មិនត្រូវនិយាយកំប្លែងបែបបៀតបៀនកេរ្តិ៍ខ្មាស់។
- មិនសំលឹងមើលដោយបង្កប់នូវអារម្មណ៍ស្រើបស្រាល ឬធ្វើអាកប្បកិរិយាដែលមានបំណងធ្វើអោយអាម៉ាសមុខ ឬបំភិតបំភ័យនរណាម្នាក់។
- មិនត្រូវបង្ហាញកាយវិការលេងសើច ឬ និយាយសំដៅលើរូបរាងកាយ អាយុ ពូជសាសន៍ ឬពិការភាព ក្នុងលក្ខណៈរើសអើង។
- មិនត្រូវនិយាយប្រមាថ ឬមិនសមរម្យដូចជា ការហៅឈ្មោះ ឬការជេប្រមាថ។
- មិនត្រូវប៉ះពាល់ដោយគ្មានការយល់ព្រមពីភាគីម្ខាងទៀតដូចជាថើប អោបរឹតការម៉ាស្សា។
- មិនត្រូវបង្ហាញសម្ភារអាសអាភៀសដូចជា poster, cartoons, graffiti, video,...ជាដើម។
-

## អំពីក្រុមប្រឹក្សាភិបាលរបស់អង្គការ

| ឈ្មោះ | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន |
|---|---|---|
| លោកស្រី ញាណ ភួងម៉ាលី | ប្រធានក្រុមប្រឹក្សាភិបាល | សៀមរាប |
| លោក សាន សារីដេត | សមាជិកក្រុមប្រឹក្សាភិបាល | សៀមរាប |
| លោក អឿ អ៊ីល | សមាជិកក្រុមប្រឹក្សាភិបាល | ភ្នំពេញ |
| លោក យូ ច័ន្ទប្រសិទ្ធ | សមាជិកក្រុមប្រឹក្សាភិបាល | ភ្នំពេញ |
| លោក សន សាមួន | សមាជិកក្រុមប្រឹក្សាភិបាល | ភ្នំពេញ |

## បុគ្គលិកលេខាធិការដ្ឋាន

| ល.រ | ឈ្មោះ | ភេទ | មុខងារ | អាស័យដ្ឋាន |
|---|---|---|---|---|
| 1 | ចេប ម៉ាលីបុប្ផា | ស្រី | នាយិកាប្រតិបត្តិ | សៀមរាប |
| 2 | ទិត សុផល្លែន | ស្រី | ប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ | សៀមរាប |
| 3 | ចាប ប៊ុនថន | ប្រុស | ប្រធានត្រួតពិនិត្យ និងវាយតម្លៃ | សៀមរាប |
| 4 | ថៃ ពិសី | ប្រុស | មន្ត្រីទំនាក់ទំនង | សៀមរាប |
| 5 | ពាង សុខា | ស្រី | រដ្ឋបាល និងគណនេយ្យករ | សៀមរាប |
| 6 | ផាន់ ចេនឡា | ស្រី | បេឡាធិការនី | សៀមរាប |
| 7 | ចក់ វត្ថា | ប្រុស | អ្នកបច្ចេកទេសវារីវប្បកម្ម | កំពង់ធំ |
| 8 | សាមុត ពីរ៉ានេរ | ស្រី | អ្នកបច្ចេកទេសវារីវប្បកម្ម | សៀមរាប |
| 9 | ប្រោញ ធារ៉ុំង | ស្រី | មន្ត្រីទីផ្សារ | សៀមរាប |
| 10 | ស៊ាង រ៉ា | ស្រី | ប្រធានក្រុមផលិតកម្ម | សៀមរាប |
| 11 | ផេង ស្រីល័ក្ខ | ស្រី | ជំនួយការផលិតកម្ម | សៀមរាប |
| 12 | ថាត់ នាង | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 13 | នូ ចន្ទី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 14 | ហាក់ ហ៊ុន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 15 | វី ចន្ថា | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 16 | ក្រាក់ ផៃ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 17 | ចាន់ រ៉ា | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 18 | ពៅ នាង | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 19 | វី ស្រីយុន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 20 | ក្រាក់ សុភា | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 21 | អ៊ឹម ចិន្តា | ស្រី | ធ្វើសាប៊ូ | សៀមរាប |

| | | | | |
|---|---|---|---|---|
| 22 | សុខ គារ៉ា | ប្រុស | ធ្វើសាប៊ូ | សៀមរាប |
| 23 | ហ៊ុក គឹមលី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 24 | ញ៉ូយ សូនី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 25 | ទុយ រិន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 26 | យង់ មី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 27 | អ៊ឹម ណារិន | ប្រុស | ធ្វើសាប៊ូ | សៀមរាប |
| 28 | ឡាយ សេដា | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 29 | ទុំ សល្យ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 30 | រ៉ាយ ស្រីមុំ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 31 | ផាត និមល | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 32 | ឃួន កែវ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 33 | ឡៃ ចាន់ម៉ៃ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 34 | សុខ ស្រីម៉េង | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 35 | កុត ប្រិច | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 36 | កន ម៉ុន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 37 | វង់ សៅម៉ៅ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 38 | ប៉ាន សុភី | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 39 | ហ៊ីង ស្រីហ៊ាក់ | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 40 | លឿម ផលលែន | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 41 | សំ បូរ៉ា | ប្រុស | ធ្វើសាប៊ូ | សៀមរាប |
| 42 | ហ៊ីង ស្រីឃួច | ស្រី | ធ្វើសាប៊ូ | សៀមរាប |
| 43 | វ៉ែន តុលា | ប្រុស | ធ្វើសាប៊ូ | សៀមរាប |

## វិស័យផ្តោតការយកចិត្តទុកដាក់

| ឈ្មោះគម្រោង | គោលដៅ | រយៈពេល | ដៃគូគម្រោង | ប្រភពថវិកា | ស្ថានភាព |
|---|---|---|---|---|---|
| គម្រោងកែច្នៃសាប៊ូ | សៀមរាប | ១០ឆ្នាំ (២០១៤-២០២៤) | អ៊ី.អ៊ែស.បី | អាមេរិក | ដំណើការ |
| គម្រោងការអភិវឌ្ឍន៍ខ្សែច្រវ៉ាក់តម្លៃត្រី | ខេត្ត សៀមរាប ខេត្ត កំពង់ធំ | ៣៦ខែ ២០២២-២០២៥ | អង្គការអាប់ជ្រា | AFD | កំពុងដំណើការ |

| | | | | | |
|---|---|---|---|---|---|
| | | | និងវិទ្យាស្ថានស្រាវជ្រាវស៊ីរ៉ាត | | |
| គម្រោងបង្កើតមណ្ឌលសិក្សាសហគមន៍ ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ីត្រី | ខេត្ត សៀមរាប | ៣ឆ្នាំ ២០២៣-២០២៥ | មជ្ឈមណ្ឌលត្រីពិភពលោក | មជ្ឈមណ្ឌលត្រីពិភពលោក | កំពុងដំណើការ |

## ២. ពត៌មានគម្រោង

### ២.១. ខេត្តសៀមរាប

មាន៣គម្រោងដែលប្រភពថវិកាមកពីម្ចាស់ជំនួយ

- **<u>គម្រោងទី១</u>**

| | |
|---|---|
| ឈ្មោះគម្រោង | ធនាគារសាប៊ូ |
| គោលបំណងរួម | ១. លើកកំពស់សេវា និងមធ្យោបាយអនាម័យស្អាត<br>២. កាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថាន<br>៣. និងលើកកម្ពស់សេដ្ឋកិច្ចស្ត្រីនៅក្នុងសហគមន៍ |
| តំបន់គោលដៅ | -ខេត្ត សៀមរាប |
| ក្រុមគោលដៅ | -ប្រជាពលរដ្ឋទូទៅដែលមានតម្រូវការប្រើប្រាស់សាប៊ូដើម្បីធ្វើអនាម័យប្រចាំថ្ងៃ |
| អ្នកទទួលផលផ្ទាល់ | -ក្រុមស្ត្រីក្រីក្រ ងាយរងគ្រោះនៅក្នុងខេត្តសៀមរាប |
| អ្នកទទួលផលប្រយោល | -សិស្សានុសិស្សនៅតាមសាលារៀន និងប្រជាសហគមន៍ |

- **<u>គម្រោងទី២</u>**

| | |
|---|---|
| ឈ្មោះគម្រោង | បង្កើតមណ្ឌលសិក្សាសហគមន៍ ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ីត្រី |
| គោលបំណងរួម | ១-ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍ស្រះជម្រកត្រី លើវិធីសាស្រ្តប្រព័ន្ធអេកូឡូស៊ីក្នុងការគ្រប់គ្រងធនធានជលផល។<br>២-បង្កើតមណ្ឌលសិក្សាសហគមន៍ត្រពាំងគុយ។<br>៣-រួមបញ្ចូលគ្នានូវផែនការគ្រប់គ្រង និងការអនុវត្តការសម្របខ្លួន។<br>៤-សាកល្បងលើវិធីសាស្រ្ត ប្រើប្រាស់ធនធានជលផលក្នុងសហគមន៍ និងកត់ត្រាការអនុវត្តល្អ ដើម្បីចែករំលែកទៅដល់សហគមន៍ដទៃ។ |
| តំបន់គោលដៅ | ខេត្តសៀមរាប (ស្រុកសូទ្រនិគម) |

| | |
|---|---|
| ក្រុមគោលដៅ | គណៈកម្មការ និងសមាជិកសហគមន៍គោលដៅ |
| អ្នកទទួលផលផ្ទាល់ | ៥៥ គ្រួសារ |
| អ្នកទទួលផលប្រយោល | ១៣១៧គ្រួសារ ស្មើ៦៧៨នាក់ |

❖ **គម្រោងទី៣**

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងការអភិវឌ្ឍន៍ខ្សែច្រវ៉ាក់តម្លៃត្រី |
| គោលបំណងរួម | ១. ពង្រឹង និងពង្រីកសក្តានុពលនៃការផលិតត្រីតាមលក្ខណៈក្សេត្របរិស្ថាន និងទទួលបានផលចំណេញខ្ពស់<br>២. លើកកម្ពស់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារជា យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍជនបទ ប្រកបដោយនិរន្តរភាពនៅតំបន់ជុំវិញបឹងទន្លេសាប |
| តំបន់គោលដៅ | ខេត្តសៀមរាប (ស្រុកក្រឡាញ់ ស្រុកសូទ្រនិគម ស្រុកបន្ទាយស្រី និងស្រុកប្រាសាទបាគង) |
| ក្រុមគោលដៅ | កសិករចិញ្ចឹមត្រី |
| អ្នកទទួលផលផ្ទាល់ | ៩៧ គ្រួសារ |
| អ្នកទទួលផលប្រយោល | ២០០គ្រួសារ ស្មើ ១៣៥០នាក់ |

## ២.២. សាខាខេត្តកំពង់ធំ

❖ **គម្រោងទី១**

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងការអភិវឌ្ឍន៍ខ្សែច្រវ៉ាក់តម្លៃត្រី |
| គោលបំណងរួម | ១.លើកកម្ពស់សុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភសម្រាប់គ្រួសារកសិករ នៅក្នុងតំបន់គោលដៅ<br>២.លើកកម្ពស់ជីវភាពរបស់ប្រជាកសិករតាមរយៈការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារបែបអេកូឡូស៊ី ប្រកបដោយនិរន្តរភាពនៅតំបន់ជុំវិញបឹងទន្លេសាប |
| តំបន់គោលដៅ | **ខេត្តកំពង់ធំ** (ស្រុកកំពង់ស្វាយ និងស្រុកសន្ទុក) |
| ក្រុមគោលដៅ | កសិករចិញ្ចឹមត្រីនៅតាមស្រះភ្ជាប់នឹងវាលស្រែ |
| អ្នកទទួលផលផ្ទាល់ | ៤៧ គ្រួសារ |
| អ្នកទទួលផលប្រយោល | ១៧០គ្រួសារ ស្មើ ៩៥០នាក់ |

## ៣. ពិពណ៌នាសង្ខេបពីការរីកចម្រើនរបស់គម្រោង

➢**គម្រោងទី១**

គម្រោងធនាគារ សាប៊ូគឺជាគម្រោងមួយដែលចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមសំខាន់ៗចំនួនបីគឺ៖

- **បញ្ហាអនាម័យ៖** ទឹកស្អាត អនាម័យខ្លួនប្រាណ និងអនាម័យក្នុងការរស់នៅ គឺជាកត្តាសំខាន់បំផុតក្នុងការរក្សាសុខភាពកុមារ និងគ្រួសារ។ ជាអកុសល អនាម័យជាញឹកញាប់ត្រូវបានគេមើលរំលង។ ស្ថានភាពអនាម័យមិនល្អគឺកាន់តែធ្ងន់ធ្ងរឡើងដោយសារកង្វះការអប់រំអនាម័យត្រឹមត្រូវ និងការប្រើប្រាស់សារធាតុជំនួសសាប៊ូដែលមិនសូវមានប្រសិទ្ធភាដូចជាផេះជាដើម។ ប្រជាជននៅតាមជនបទមួយចំនួនមានទំនោរទៅងូតទឹក និងលាងដៃដោយប្រើសាប៊ូបោកខោអាវដែលមានសារធាតុគីមីពុលដែលអាចជ្រាបចូលតាមស្បែកបាន។
- **បញ្ហាបរិស្ថាន៖** ជាធម្មតា ដុំសាប៊ូដែលប្រើរួចទាំងអស់ពីក្រុមហ៊ុនផលិតត្រូវបានបោះចោល ហើយបញ្ជូនទៅកន្លែងចាក់សំរាម។ នេះគឺជាបរិមាណដ៏សំខាន់នៃសម្ភារៈដែលមិនអាចបំបែកបាន។
- **បញ្ហាសេដ្ឋកិច្ច ជាពិសេសសម្រាប់ស្ត្រីក្រីក្រ៖** ក្នុងប្រទេសកម្ពុជាក៏ប្រឈមនឹងបញ្ហាជាច្រើនដែរ។ ការងារស្ថិរភាពសម្រាប់ស្ត្រីគឺជាបញ្ហាសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរបំផុតមួយ។ ជាពិសេសស្ត្រីដែលមកពីមជ្ឈដ្ឋានដែលមានការលំបាក និងមិនមានប្រភពចំណូលដែលអាចទុកចិត្តបានផ្សេងទៀត។

យើងជឿជាក់លើការលាងដៃ ព្រោះវាត្រូវបានបង្ហាញថាអាចកាត់បន្ថយវត្តមានបាក់តេរីដែលបង្កគ្រោះថ្នាក់ដល់ទៅ ៩២%។ ហើយប្រទេសកំពុងអភិវឌ្ឍនៅតែបន្តតស៊ូជាមួយនឹងអត្រាមរណៈរបស់កុមារខ្ពស់ តាមការប៉ាន់ប្រមាណថាកុមារ ១១នាក់ ដែលមានអាយុក្រោម ៥ឆ្នាំ បានស្លាប់រៀងរាល់នាទីក្នុងឆ្នាំ ២០១៥។ តាមដែលយើងឃើញ សាប៊ូគឺជាធនធានមនុស្សដ៏សំខាន់មួយ។ អង្គការអ្នកត្រួសត្រាយនៃកម្ពុជា បានស្វែងរកការកាត់បន្ថយកាកសំណល់នេះ ក្នុងការបម្រើបញ្ហាអនាម័យជាសាកលដ៏ធ្ងន់ធ្ងរ ហើយកែច្នៃសាប៊ូទៅជាដុំថ្មី ហើយចែកចាយវាទៅសាលារៀន អង្គការក្រៅរដ្ឋាភិបាល និងប្រជាជនដែលងាយរងគ្រោះ តាមរយៈការជួលពួកគេដោយប្រាក់ឈ្នួលសមរម្យ យើងសង្ឃឹមថានឹងសម្រាលបន្ទុករបស់ពួកគេ និងជួយគ្រួសាររបស់ពួកគេ។ សាប៊ូក្លាយជាផលិតផលដែលផលិតដោយ និងសម្រាប់សហគមន៍មូលដ្ឋាន ហើយស្ត្រីអាចមានអារម្មណ៍ល្អក្នុងការងារដើម្បីជាប្រយោជន៍ដល់អ្នកដែលត្រូវការជំនួយ។ យើងមានមោទនភាពក្នុងការផ្តល់នូវផលិតផលដែលមានគុណភាពខ្ពស់ ភាពសប្បាយរីករាយ និងបរិស្ថានដែលអាចមានឥទ្ធិពលវិជ្ជមាន និងលើកកំពស់ដល់សុខុមាលភាពសហគមន៍។

| **គម្រោង** | **លទ្ធផលរំពឹងទុកឆ្នាំ២០២៣** |
| --- | --- |
| គម្រោងកែច្នៃសាប៊ូ | • សាប៊ូដែលគេប្រើប្រាស់រួចត្រូវបានប្រមូលយកមកកែច្នៃឡើងវិញ<br>• ស្ត្រី និងកុមារងាយរងគ្រោះនឹងទទួលបានសាប៊ូប្រើប្រាស់<br>• ក្រុមស្ត្រីចំនួន ៣០នាក់ ទទួលបានការងារធ្វើ និងប្រាក់ចំណូលសមរម្យ |
| **លទ្ធផលសម្រេចបានឆ្នាំ ២០២៣** | |

- បានកែច្នៃប្រភេទសាប៊ូម៉ាស៊ីនដុំ សរុបចំនួន ៥៧៤,២៥៥ ដុំ
- បានកែច្នៃប្រភេទសាប៊ូដៃ សរុបចំនួន ៣៣៨,៦២៣ ដុំ
- បានកែច្នៃប្រភេទសាប៊ូរូប សរុបចំនួន ១៣៧,០៨៩ ដុំ
- បានចែកសាប៊ូទៅអង្គការដៃគូចំនួន៣១ ស្មើនឹងសាប៊ូចំនួន៥៧៦,៦១៥ ដុំ
- បានចែកសាប៊ូទៅសាលារៀនចំនួន០៧ ស្មើនឹងសាប៊ូចំនួន២៦,៣៧៥ ដុំ
- ស្ត្រីក្រីក្រចំនួន ៣០នាក់ និងបុរស ចំនួន៤នាក់ ទទួលបានការងារធ្វើ និងមានប្រាក់ចំណូលសមរម្យ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ និងផ្តល់លទ្ធភាពឲ្យកូនៗរបស់ពួកគេទទួលបានការសិក្សាពេញលេញ។

➢ **គម្រោងទី២**

គម្រោងបង្កើតមណ្ឌលសិក្សាសហគមន៍ ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ីត្រី គឺជាវិធានការណ៍ឆ្លើយតប ទៅនឹងបញ្ហាប្រឈម ដែលយើងកំពុងជួបប្រទះគឺ ការកើនឡើងចំនួនប្រជាជនបានបង្កើនសម្ពាធលើការ នេសាទ ការបង្កើនការធ្វើស្រែកាន់តែខ្លាំងក្លា និងការបំផ្លាញជម្រករបស់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិទាំងអស់ ដែលរួមចំណែកដល់ការថយចុះទិន្នផល និងជីវចម្រុះ។ គម្រោងនេះ បង្កើតឡើងក្នុងគោលបំណងបង្កើន ជីវចម្រុះនៅក្នុងទឹក ជាពិសេសគឺត្រី តាមរយៈការបង្កើនការយល់ដឹង និងចំណេះដឹងរបស់សហគមន៍ អំពីវិធីសាស្រ្តនៃប្រព័ន្ធអេកូឡូស៊ីចំពោះគោលគំនិតនៃការគ្រប់គ្រងជលផល។ លទ្ធផលគ្រោងសំខាន់ៗចំនួនបួនដែលយើងចង់បានគឺៈ(1) ធ្វើអោយប្រសើរឡើងនូវសមត្ថភាពរបស់គណៈកម្មការសហគមន៍ ស្រះ ជម្រកត្រី អ្នកភូមិ និងអាជ្ញាធរមូលដ្ឋាននៅក្នុងតំបន់គោលដៅ តាមរយៈការអនុវត្តន៍នូវវិធីសាស្រ្តគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីសម្រាប់ធនធានជលផល។ (២) បង្កើតមជ្ឍមណ្ឌលសិក្សាសហគមន៍មួយជាការសាកល្បង នៅឯសហគមន៍ស្រះជម្រកត្រីត្រពាំងគុយ; (3) រួមបញ្ចូលផែនការគ្រប់គ្រងការសម្របសម្រួល និងការអនុវត្ត សម្រាប់សហគមន៍ស្រះជម្រកត្រី; និង (4) សាកល្បងលើវិធីសាស្រ្តចែករំលែកការចាប់ដល់សហគមន៍ និង កត់ត្រាការអនុវត្តល្អបំផុតរបស់ពួកគេ។

| **គម្រោង** | **លទ្ធផលរំពឹងទុកឆ្នាំ២០២៣** |
|---|---|
| បង្កើតមណ្ឌលសិក្សាសហគមន៍ ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ីត្រី | • មណ្ឌលសិក្សាសហគមន៍១ត្រូវបានបង្កើតឡើង ដែលជាកន្លែងសិក្សាស្រាវជ្រាវ<br>• ចំណេះដឹង និងសមត្ថភាពរបស់គណៈកម្មការសហគន៍នឹងមានការកើនឡើង ទាំងការរៀបចំចាត់ចែង និងការគ្រប់គ្រង។ |

**លទ្ធផលសម្រេចបានឆ្នាំ ២០២៣**

- **សកម្មភាពសំខាន់ៗក្នុងគម្រោង**
  - ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្រ្តប្រព័ន្ធអេកូក្នុងការគ្រប់គ្រងធនធានជលផលដល់សហគមន៍គោលដៅ
  - ជ្រើសរើសជនបង្គោលក្នុងសហគមន៍
  - រៀបចំបទប្បញ្ញត្តិរបស់មណ្ឌលសិក្សាសហគមន៍

- បន្សុំផែនការគ្រប់គ្រង និងផែនការសម្របខ្លួនរបស់សហគមន៍
- គាំទ្រសកម្មភាពអន្តរាគមន៍របស់សហគមន៍
- ពិភាក្សាអំពីវិធីសាស្ត្រប្រើប្រាស់ធនធានជលផលក្នុងសហគមន៍
- ធ្វើការជាមួយអ្នកនេសាទ ដើម្បីតាមដានការចាប់ត្រី
- ចងក្រងឯកសារដំណើរការនៃការចាប់-ចែករំលែក និងចែករំលែកជាមួយសហគមន៍ផ្សេងទៀត

- **លទ្ធផលសម្រេចបានឆ្លើយតបនឹងសកម្មភាព**
  - o រៀបចំកិច្ចប្រជុំផ្សព្វផ្សាយពីគម្រោង ទៅខណ្ឌជលផល (FiAC) អាជ្ញាធរមូលដ្ឋាន គណៈកម្មការសហគមន៍ស្រះជម្រកត្រី និងសហគមន៍នេសាទ (CFRCs CFiCs) និងប្រជាពលរដ្ឋក្នុងតំបន់គោលដៅមានអ្នកចូលរួមសរុប ចំនួន២៩នាក់ ស្ត្រី៩នាក់
  - o ប្រជុំជាមួយក្រុមកាងារគម្រោង ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាល និងសម្ភារៈ
  - o ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រប្រព័ន្ធអេកូក្នុងការគ្រប់គ្រង ធនធានជលផលដល់សហគមន៍គោលដៅ (មន្ត្រីរដ្ឋបាលជលផល គណៈកម្មាការសហគមន៍ស្រះជម្រកត្រី និងសហគមន៍នេសាទបាន៦វគ្គ (៤វគ្គដោយផ្ទាល់ និង២វគ្គអនឡាញ)លើ៤ប្រធានបទៈ
    - ទស្សនទានអេកូឡូស៊ីត្រី
    - ផែនការអភិវឌ្ឍមណ្ឌលសិក្សាសហគមន៍
    - ការគ្រប់គ្រងធនធានជលផលតាមវិធីសាស្ត្រអេកូឡូស៊ី (EAFM)
    - ការស្រាវជ្រាវអេកូឡូស៊ីត្រី និងប្រមូលទិន្នន័យត្រី
  - o វិភាគស្ថានភាពទូទៅរបស់សហគមន៍ទេសាទ និងសហគមន៍ស្រះជម្រកត្រី
    - ព័ត៌មានទូទៅ
    - ទិដ្ឋភាព និងប្រព័ន្ធអេកូឡូស៊ីសំខាន់ៗនៃ CFRs, Cfis
    - វាលស្រែភ្ជាប់ជាមួយនឹង CFRs និងCfis
    - ការកៀរគរថវិការបស់ CFRs និងCFis, និងធនធានដែលអាចប្រើបានសម្រាប់ គាំទ្រ
  - o រៀបចំផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីការកៀរគរធនធាន និងថវិកានៅសហគមន៍នេសាទ ថ្នល់ដាច់លិច ស្ថិតនៅភូមិថ្នល់ដាច់លិច ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប មានអ្នកចូលរួមសរុប១៥នាក់ ស្រី៣នាក់( មន្ត្រីជលផល គណៈកម្មាការសហគមន៍នេសាទ)
  - o រៀបចំការប្រជុំជ្រើសរើសគណៈកម្មការចំនួន០៧រូប សម្រាប់មណ្ឌលសិក្សាសហគមន៍ចេញពីគណៈកម្មការសហគមន៍ស្រះជម្រកត្រីចំនួន០៤ (ត្រពាំងគុយ ត្រពាំងភ្លោះ ត្រពាំងខ្វារកន្ទ្រាំង គីឡូម៉ែត្រលេខ៨) និងសហគមន៍នេសាទថ្នល់ដាច់ ដែលមានអ្នកចូលរួមសរុប២៦នាក់ ស្រី៣នាក់
  - o រៀបចំគោលការណ៍ និងបទបញ្ជាផ្ទៃក្នុងសម្រាប់មណ្ឌលសិក្សាសហគមន៍
  - o រៀបចំកិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន និងសមាជិកមណ្ឌលសិក្សាសហគមន៍ ដើម្បីពិនិត្យ

លើសេចក្តីព្រាងលក្ខន្តិកៈ និងស្នើសុំដីកាសម្រេចទទួលស្គាល់គណៈកម្មាការ

- បានរៀបចំធ្វើបច្ចុប្បន្នភាពលក្ខន្តិកៈ និងបានចុះហត្ថលេខាទទួលស្គាល់ដោយប្រធានក្រុមប្រឹក្សាឃុំជានរុន
- គាំទ្រគណៈកម្មការ CFi/CFR ទៅចូលរួមសិក្ខាសាលាចែករំលែកមេរៀន និង ក្នុងប្រជុំបណ្តាញ Cfiស្តីពី"ការពង្រឹងអភិបាលកិច្ចល្អ និងប្រសិទ្ធិភាពក្នុងការគ្រប់គ្រងធនធានជលផលក្រោមប្រធានបទ" អភិបាលកិច្ចល្អក្នុងវិស័យជលផលប្រកបដោយននិរន្តភាព" មានអ្នកចូលរួមសរុប១៨៥នាក់ស្រី៣២នាក់

➢ **គម្រោងទី៣**

អង្គការអ្នកត្រួសត្រាយនៃកម្ពុជា បានសហការជាមួយអង្គការអាប់ជ្រា ដោយមានការគាំទ្រថវិកាពី ទីភ្នាក់ងារអភិវឌ្ឍបារាំង ក្នុងការអនុវត្តន៍គម្រោងនេះ។ គម្រោងនេះ ត្រូវបានអនុវត្តដោយដៃគូនៅក្នុងប្រទេស៤ ផ្សេងទៀតនៅទ្វីបអាហ្វ្រិក ដូចជាប្រទេស កុងហ្គោ ម៉ាដាកាស្កា កូដវ័រ និង កាម៉ារ៉ូន។ គម្រោងនេះ មានគោលបំណងក្នុងការលើកកម្ពស់ ការចិញ្ចឹមត្រីតាមបែបកេ្សត្របរិស្ថាន ប្រកបដោយនិរន្តិ៍ភាព។

| **គម្រោង** | **លទ្ធផលរំពឹងទុកឆ្នាំ២០២៣** |
|---|---|
| អភិវឌ្ឍន៍ខ្សែរសង្វាក់តម្លៃត្រីនៅកម្ពុជា | • ដើម្បីលើកកម្ពស់ការចិញ្ចឹមត្រី ជាលក្ខណៈគ្រួសារបែបអេកូឡូស៊ី ប្រកបដោយនិរន្តរភាពនៅតំបន់ជុំវិញបឹងទន្លេសាប។<br>• ប្រជាកសិករចូលរួមក្នុងការសាកល្បងនូវបច្ចេកទេសចិញ្ចឹមត្រី ភ្ជាប់នឹងវាលស្រែ។ |

**លទ្ធផលសម្រេចបានឆ្នាំ ២០២៣**

- បានធ្វើការចុះត្រួតពិនិត្យតាមដានយ៉ាងយោចណាស់ម្តងក្នុងសប្តាហ៍ គឺផ្តោតសំខាន់ទៅលើៈ
  - ការធ្វើដែនការចិញ្ចឹមក្នុងកសិដ្ឋានឡើងវិញ
  - ការតាមដានការឱ្យចំណី
  - ការកត់ត្រទិន្នន័យ
  - ការធ្វើប្លង់បង្ហាញ
  - ការដាក់កូនត្រី និងផលិតកម្ម
- ផ្តល់វគ្គបណ្តុះបណ្តាលជាទៀងទាត់ លើប្រធានបទដែលឆ្លើយតបនឹងសំណើរ និងតម្រូវការរបស់ពួកគេ ដែល២៩វគ្គ មានអ្នកចូលរូមសរុបចំនួន២៣៩នាក់ ស្រី៧៥នាក់ យុវជន១០នាក់ ក្នុងនោះមានៈ
  - មូលដ្ឋានគ្រិះនៃការចិញ្ចឹមត្រី មាន៧វគ្គ អ្នកចូលរួមសរុប៥៤/ស្រី២៤នាក់ យុវជន២នាក់
  - ការកត់ត្រាទិន្នន័យដើម្បីគ្រប់គ្រងសេដ្ឋកិច្ច មាន៧វគ្គ អ្នកចូលរួមសរុប៥១/ស្រី១៥នាក់ យុវជន២នាក់

- យុទ្ធសាស្ត្រនៃការប្រើប្រាស់ចំណី មាន៨វគ្គ អ្នកចូលរួម៧៦នាក់ ស្រី២៣នាក់ យុវជន៣នាក់
- ការឱ្យចំណីត្រីទៅតាមចរិកលក្ខណៈធម្មជាតិ មាន៣វគ្គ អ្នកចូលរួម២៧នាក់ស្រី៥នាក់ យុវជន២នាក់
- វិធីសាស្ត្រពិនិត្យត្រីទីឡាបព្យាញីឈ្មោល មាន៤វគ្គ អ្នកចូលរួម៣១/ស្រី៨នាក់ យុវជន០១នាក់

o សម្របសម្រួលធ្វើទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរ

បទពិសោធន៍មានតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកចំណេះដឹង និងបង្កើតថ្មីរវាងកសិករ និងកសិករ មាន១៣វគ្គ អ្នកចូលរួម១៤៥នាក់ ស្រី៣៣នាក់ យុវជន៩នាក់ រួមមាន៖

- ទស្សនៈកិច្ចសិក្សា ជាទៀងទសត់រវាងអ្នកផលិត និងទីផ្សាត្រី មាន៩វគ្គ អ្នកចូលរួម៨៨នាក់ ស្រី២៣នាក់ យុវជន៦នាក់
- ទស្សនៈកិច្ចសិក្សាទៅកាន់កសិដ្ឋានបង្កាត់ត្រី មាន១វគ្គ អ្នកចូលរួម៥នាក់ស្រី០នាក់
- ទស្សនៈកិច្ចសិក្សាទៅកាន់កសិដ្ឋានផ្គត់ផ្គង់ត្រីដ៏ធំដោយអ្នកទទួលផល មាន៣វគ្គ អ្នកចូលរួម៥២នាក់ស្រី១០នាក់ យុវជន៣នា

o ប្រជុំគណៈកម្មការបច្ចេកទេស ដើម្បីពិភាក្សាពីភាពសកម្មក្នុងការអភិវឌ្ឍខ្លួនឯង ហើយព្យាយាមស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈម៖

- ការកំណត់ពីបញ្ហាប្រឈម មាន៤វគ្គ អ្នកចូលរួម២៩នាក ស្រី១៤នាក់ យុវជន៤នាក់
- ការដោះស្រាយបញ្ហាជាក់លាក់ មាន៥វគ្គ (អ្នកចូលរួម៥១នាក់ ស្រី ២៦នាក់ យុវជន២នាក់) ក្នុងនោះរួមបញ្ចូលនូវប្រធានបទមួយចំនួនដូចជា៖ ការដាកើកូនត្រី កត្តាទឹក ចំណី ទីផ្សា និងទីតាំង
- វិភាគលទ្ធផលនៃការចិញ្ចឹមដោយដាក់ទ្រុង ១វគ្គ អ្នកចូលរួម៣នាក់ ស្រី០នាក់ យុវជន០០នាក់

o ការពង្រឹកសមត្ថភាពបុគ្គលិក

- ការភ្ជាប់បណ្តាញត្រូពិច និងអេកូឡូស៊ីស្រះ ១វគ្គ
- ឧបករណ៍នៃការធ្វើផែនការវដ្តនៃការចិញ្ចឹមត្រី ១វគ្គ
- ការត្រួតពិនិត្យការលូតលាស់របស់ត្រី តារាងចំណី និងលទ្ធផលនៃការចិញ្ចឹមត្រីក្នុងអាង/បែរ១វគ្គ
- ការរៀបចំយុទ្ធសាស្ត្រចិញ្ចឹមត្រី ១វគ្គ
- របៀបនៃការរៀបចំប្លង់របស់កសិករ ១វគ្គ
- យុទ្ធសាស្ត្រនៃការប្រើចំណី៣វគ្គ
- មូលដ្ឋានគ្រឹះនៃការបង្កាត់ត្រីទីឡាបព្យា(បង្ហាញដោយលោក វិបុល) ១វគ្គ
- លទ្ធផលនៃការស្ទង់មតិលើគោលបំណងរបស់កសិករ(បង្ហាញដោយកញ្ញា ពីរ៉ានេរ) ១វគ្គ

| - បច្ចេកទេសនៃការកត់ត្រាទិន្នន័យ និងការគ្រប់គ្រងហិរញ្ញវត្ថុ ១វគ្គ |
|---|

## ៤. របាយការណ៍ហិរញ្ញវត្ថុ

អង្គការអ្នកត្រួសត្រាយនៃកម្ពុជា បានកំណត់យក ខែ មករា ដល់ ខែ ធ្នូ ជាឆ្នាំសារពើពន្ធ សម្រាប់ឆ្នាំនីមួយៗ។ ខាងក្រោមនេះគឺជារបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២៣៖

| **របាការណ៍ហិរញ្ញវត្ថុ** | **២០២៣** |
|---|---|
| **មូលនិធិ** | |
| -មូលនិធិយោងពីឆ្នាំ ២០២២ | ១២៦,២៥២,000 រៀល |
| -មូលនិធិពីម្ចាស់ជំនួយសរុប | ១,៧៨៤,០៧២,៩00រៀល |
| **មូលនិធិសរុប** | ១,៨៧០,៣២៤,៩00រៀល |
| **ការចំណាយរបស់គម្រោង** | |
| -អភិវឌ្ឍខ្សែច្រវ៉ាក់តម្លៃត្រីនៅកម្ពុជា | ៣៤៧,៩៧៩,៤00 រៀល |
| -ធនាគារសាប៊ូ | ១,៣៣៤,២៧៦,៤00រៀល |
| -បង្កើតមណ្ឌលសិក្សាសហគមន៍ ដើម្បីធ្វើឲ្យប្រសើរឡើងនូវអេកូឡូស៊ីត្រី | ១៥,៨៥១,៣00 រៀល |
| -សកម្មភាពប្រតិបត្តិការ និង រដ្ឋបាល | ៨១,៤៧៧,500 រៀល |
| **ការចំណាយសរុប** | ១,៧៧៩,៥៨៤,៦00 រៀល |
| **សមតុល្យសរុប** | ៩០,៧៤០,៣00 រៀល |

## ៥. បញ្ហាប្រឈម និង មេរៀនបទពិសោធន៍

### ៥.១ បញ្ហាប្រឈម

- ពិបាកក្នុងការសំបកកេសសម្រាប់ខ្ចប់សាប៊ូ
- មិនទាន់មានរូបមន្តលាយក្លិនជាក់លាក់(ខ្វះបច្ចេកទេស)
- សាប៊ូដែលផលិតហើយមួយចំនួនមិនស្អួត ដោយសារវត្ថុធាតុដើមមានជាតិប្រេងច្រើន
- មិនសូវមានកសិករចាប់អារម្មណ៍ក្នុងការអនុវត្តគម្រោង (កញ្ចប់ថវិកាបដិភាគតិច)
- កសិករខ្លះមិនបានកត់ត្រាការចំណាយឱ្យបានត្រឹមត្រូវ
- ស្រះកសិករខ្លះមិនបានប្រមូលផលត្រីដោយរដូវវស្សាចូលមកដល់(ភ្លៀងបន្តបន្ទាប់)
- គុណភាពទឹកស្រះមួយចំនួនមិនល្អ មានល្បាប់ដីច្រើន ជាបញ្ហារំខានដល់ការលូតលាស់របស់ត្រី
- ការភ្ជាប់ទៅកាន់ទីផ្សារ ការជ្រើសរើសពូជដែលមានតម្លៃទាប ការប្រមូលផលខុសរដូវកាល

កង្វះទំនាក់ទំនងទៅអ្នកទិញ និងស្ទូវមានឈ្មួញកណ្តាល

- ចំនួនគណៈកម្មាការស្រះជម្រកត្រីខ្លះមិនមានអ្នកចូលរួមពីព្រោះគណៈកម្មាការចំណាកស្រុកទៅខេត្តផ្សេង
- មិនទាន់មានគោលការណ៍រួមក្នុងការបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍ និងជាវិធីសាស្ត្រថ្មីសម្រាប់ សហគមន៍ និងអាជ្ញាធរ ដូច្នេះ យើងនឹងធ្វើវា ហើយរៀនអំពីវាក្នុងពេលតែមួយ។

## ៥.២ បទពិសោធន៍ ឬមេរៀនដែលរៀនសូត្រពីគម្រោង

- ❖ ក្នុងដំណើរការបង្កើតមជ្ឈមណ្ឌលសិក្សា ការចូលរួមពីខណ្ឌរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន គឺជាការជម្រុញ និងលើកទឹកចិត្តដ៏ធំធេងសម្រាប់គណៈកម្មការក្នុងការប្តេជ្ញាចិត្ត ដើម្បីសម្រេចបាននូវការងារនេះ។ ហើយនេះវាក៏បង្ហាញទៅដល់អ្នកពាក់ព័ន្ធផ្សេងទៀត ជាពិសេសសម្រាប់សមាជិករបស់មណ្ឌលសិក្សាសហគមន៍ថា យើងជាស្ថាប័នដែលធ្វើការប្រកបដោយទំនួលខុសត្រូវ និងគណនេយ្យភាពផងដែរ។
- ❖ ស្រះសេដ្ឋកិច្ចត្រូវបានប្រើប្រាស់សម្រាប់រកប្រាក់ចំណូលសម្រាប់សហគមន៍។ វាស្ថិតនៅក្នុងតំបន់ទទួលរងឥទ្ធិពលនៃស្រះជម្រកត្រីសហគមន៍ ប៉ុន្តែមិនជាប់ដោយផ្ទាល់នោះទេ។ សហគមន៍ស្រះជម្រកត្រីត្រពាំងភ្លោះ ស្ថិតក្នុងភូមិសន្ទែ ឃុំដារុន ស្រុកសូទ្រនិគម ខេត្តសៀមរាប ផ្នែកមួយដែលនៅជិតនឹងស្រះសហគមន៍នេះ ត្រូវបានប្រជាជន និងអាជ្ញាធរមូលដ្ឋាន ព្រមទាំងមន្ត្រីនៃមន្ទីរជំនាញ ឯកភាពគ្នាថាគឺជាស្រះសេដ្ឋកិច្ច។ ស្រះសេដ្ឋកិច្ចនេះមិនត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទលក្ខណៈឯកជននោះទេ។ ស្រះនេះ ត្រូវបានប្រើប្រាស់ដោយសហគមន៍សម្រាប់បង្កើតប្រាក់ចំណូលតាមរយៈការដេញថ្លៃ។ ការដេញថ្លៃនេះត្រូវបានរៀបចំម្តងក្នុងរយៈពេលបីឆ្នាំ។មេភូមិនឹងប្រកាសប្រាប់អ្នកភូមិទាំងអស់អំពីកាលវិភាគដេញថ្លៃ និងដំណើរការ។ នៅក្នុងការប្រជុំនេះ អ្នកគ្រប់គ្នាអាចធ្វើការដេញថ្លៃបាន។ អ្នកដែលផ្តល់តម្លៃខ្ពស់បំផុតគឺជាអ្នកឈ្នះ។ បន្ទាប់មកគេអាចចាប់ត្រី និងសត្វក្នុងទឹកផ្សេងទៀតក្នុងស្រះសេដ្ឋកិច្ចដើម្បីលក់រយៈពេល៣ឆ្នាំក្នុងបរិមាណដូចគ្នា ។ កិច្ចព្រមព្រៀងមួយត្រូវបានធ្វើឡើងរវាងតំណាងសហគមន៍ និងអ្នកដេញថ្លៃនៅចំពោះមុខអ្នកចូលរួមក្នុងកិច្ចប្រជុំ។

## ៦. ផែនការទិសដៅការងារបន្ត

**<u>គម្រោងទី១៖</u>**

- សិក្សាស្វែងរករូបមន្តដើម្បីធ្វើការកែលម្អគុណភាពសាប៊ូ ក្លិន នឹងពណ៌
- បន្តផលិតឱ្យគ្រប់ផែនការដែលនៅខ្វះ

**<u>គម្រោងទី២៖</u>**

- ជម្រុញការដាក់ជីសម្រាប់បង្កើនគុណភាពទឹកក្នុងករណីស្រះណាមានការប្រែប្រួល

- ណែនាំកសិករឱ្យរៀបចំប្រព័ន្ធចិញ្ចឹមត្រីដែលមានលក្ខណៈច្នៃប្រឌិត សមស្របនឹងលទ្ធភាពរបស់កសិករ
- បន្តជម្រុញសកម្មភាពរបស់កសិករត្រូវកត់ត្រាចំណូល និងចំណាយឱ្យបានច្បាស់លាស់
- បន្តធ្វើការតាមដាន និងលើកទឹកចិត្តកសិករ
- បន្តជ្រើសរើសកសិករដើម្បីចូលរួមជាមួយគម្រោងបន្ថែមទៀត
- រៀបចំផ្តល់វគ្គបណ្តុះបណ្តាលដល់កសិករថ្មីស្តីពីបច្ចេកទេសចិញ្ចឹមត្រី
- រៀបចំទស្សនៈកិច្ចសិក្សាផ្លាស់ប្តូបទពិសោធន៍រវាងកសិករ និងកសិករ
- បន្តសិក្សាពីគោលបំណងរបស់កសិករ និងបញ្ហាប្រឈម
- បណ្តុះបណ្តាលប្រព័ន្ធអេកូឡូស៊ីត្រី និងគ្រងគ្រងធនធានជលផលទៅសហគមន៍ស្រះជម្រកត្រី និងសគមន៍នេសាទ
- ប្រជុំពិភាក្សាជាមួយខណ្ឌរដ្ឋបាលជលផល និងអាជ្ញាធរ ព្រមគណៈកម្មាការសហគមន៍ស្រះជម្រកត្រីពីវិធីសាស្ត្រនៃការចាប់ត្រី
- ផ្សព្វផ្សាយដល់សមាជិកសហគមន៍ស្តីអំពី ការចែករំលែកដំណើរការនៃចាប់ត្រី
- ធ្វើការជាអ្នកនេសាទ និងត្រួតពិនិត្យការដំណើរការនៃការប្រមូលទិន្នន័យនៃការចាប់ត្រី

**<u>គម្រោងទី៣៖</u>**

- ផ្តល់វគ្គបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រី ភ្ជាប់នឹងវាលស្រែជាលក្ខណៈគ្រួសារ
- កែលម្អរប្រព័ន្ធស្រះចិញ្ចឹមត្រី វាលស្រែ និងប្រឡាយតភ្ជាប់សម្រាប់កសិករក្នុងគម្រោង
- រៀបចំកិច្ចប្រជុំជាមួយកសិករចាស់ និងថ្មីចំនួន២៣លើកក្នុងតំបន់គោលដៅ
- សម្របសម្រួលការធ្វើផែនការដើម្បីកែលម្អយុទ្ធសាស្ត្រទីផ្សាររបស់កសិករ
- សិក្សាអំពីខ្សែច្រវ៉ាក់តម្លៃត្រីនៅខេត្តកំពង់ធំ និងសៀមរាប
- ផ្តល់ឱកាសដល់និស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាប័ត្រ ឱ្យសរសេរសារណាបទថ្នាក់បរិញ្ញាបត្រ និងសរសេរនិក្ខេបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ថ្ងៃ ចន្ទ ២ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ពស ២៥៦៧
ត្រូវនឹងថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយិកាប្រតិបត្តិ**

**ចេម ម៉ាលីបុប្ផា**

## ៧. ឧបសម្ព័ន្ធ៖

សកម្មភាព និងដំណើរការនៃការផលិត និងការវេចខ្ចប់សាប៊ូ











ប្រជុំពង្រាងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់មណ្ឌលសិក្សាសហគមន៍



ការស្រាវជ្រាវអេកូឡូស៊ីត្រី និងប្រមូលទិន្នន័យត្រី



សកម្មភាពពិនិត្យត្រីទីឡាបព្យាញីឈ្មោល



សកម្មភាពទស្សនៈកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធន៍

